**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៧៤...អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និងមាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីធនាគារអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានកែសម្រួលតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានប្តូរឈ្មោះទៅជា "**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**" ដែលសរសេរជាអក្សរកាត់ថា "**ធ.អ.ជ.ក.**" និង សរសេរជាភាសាអង់គ្លេសថា "Agricultural and Rural Development Bank" ដែលសរសេរអក្សរកាត់ជាភាសាអង់គ្លេសថា "ARDB"។

**មាត្រា២.-**

**ធ.អ.ជ.ក.** ត្រូវបានកំណត់ថាជាសហគ្រាសសាធារណៈ ក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជា ធនាគារពាណិជ្ជ និងមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ខ្លួន។

**ធ.អ.ជ.ក.** មានគោលដៅផ្តល់សេវាធនាគារពេញលេញប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីគាំទ្រវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

**ធ.អ.ជ.ក.** មានភារកិច្ចដូចតទៅ៖

- បំពេញតួនាទីជាធនាគារពាណិជ្ជផង និងជាធនាគារគោលនយោបាយផង
- ផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាក់ព័ន្ធ រួមមាន សេវាឥណទាន សេវាទូទាត់ និងសេវាទទួលប្រាក់បញ្ញើដល់អតិថិជនគោលដៅក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្ម និងសេដ្ឋកិច្ចជនបទ

- ផ្តល់ការគាំទ្រជាគោលនយោបាយលើផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស រួមមាន ការសម្របសម្រួល និងដោះស្រាយបញ្ហា ក្នុងខ្សែច្រវាក់ផលិតកម្ម វិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ តាមរយៈការស្វែងរកទីផ្សារ ការផ្តល់យោបល់ និងការកសាងសមត្ថភាពជាដើម
- លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យា និងភាពច្នៃប្រឌិត ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវា និងបង្កើនឧត្តមភាពប្រកួតប្រជែងរបស់អតិថិជនក្នុងទីផ្សារ
- សហការ និង/ឬធ្វើសហជីវការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុជាតិ និងអន្តរជាតិ ក្នុងការផ្តល់ហិរញ្ញប្បទាន ឬ អនុវត្តគម្រោងពាក់ព័ន្ធនឹងវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ
- អនុវត្តគម្រោងហិរញ្ញប្បទាន ឬ គ្រប់គ្រងមូលនិធិផ្សេងទៀត ក្នុងក្របខណ្ឌនៃកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន
- គ្រប់គ្រងកម្មវិធី ឬ គម្រោងអន្តរាគមន៍របស់រាជរដ្ឋាភិបាល
- កៀរគរទុន និងហិរញ្ញប្បទាន សម្រាប់ពង្រីកសកម្មភាពរបស់ **ធ.អ.ជ.ក.**
- ផ្តល់សេវាធនាគារផ្សេងទៀត ពាក់ព័ន្ធនឹងការគ្រប់គ្រង និងចាត់ចែងធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពជូនអតិថិជនគោលដៅ ព្រមទាំងប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ និងការទទួលខុសត្រូវសង្គមនិងបរិស្ថាន និង
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ **ធ.អ.ជ.ក.** ឱ្យមានប្រសិទ្ធភាព។

**មាត្រា៤.-**

**ធ.អ.ជ.ក.** ត្រូវស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិ នៃកម្ពុជា។

**មាត្រា៥.-**

**ធ.អ.ជ.ក.** មានប្រភពទុនមកពី÷

- ដើមទុនចុះបញ្ជីដំបូង និងដើមទុនផ្សេងទៀតដែលផ្តល់និងបន្ថែមដោយរដ្ឋ
- ប្រាក់ដែលបានមកពីការខ្ចីបុល ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់អំណោយផ្សេងៗ ឬ ប្រភពទុនស្របច្បាប់ផ្សេងទៀតដោយមានការឯកភាពពីរាជរដ្ឋាភិបាល និង
- ចំណូលផ្សេងៗគ្រប់ប្រភេទដែលបានមកពីប្រតិបត្តិការរបស់ **ធ.អ.ជ.ក.**។

**មាត្រា៦.-**

ទីស្នាក់ការកណ្តាលរបស់ **ធ.អ.ជ.ក.** ស្ថិតនៅរាជធានីភ្នំពេញ និងអាចមានសាខា ឬការិយាល័យសេវាតាមការចាំបាច់។

## ជំពូកទី ២
## ការដឹកនាំគ្រប់គ្រង

**មាត្រា៧.-**

**ធ.អ.ជ.ក.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសមាសភាពដូចតទៅ÷

| | | | |
|---|---|---|---|
| ១. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | ប្រធាន |
| ២. | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| ៣. | អគ្គនាយក **ធ.អ.ជ.ក.** | | សមាជិក |
| ៤. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| ៥. | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| ៦. | តំណាងបុគ្គលិករបស់ **ធ.អ.ជ.ក.** | ០១រូប | សមាជិក |
| ៧. | តំណាងពីវិស័យឯកជន | ០១រូប | សមាជិក |

**មាត្រា៨.-**

**ធ.អ.ជ.ក.** ត្រូវគ្រប់គ្រងដោយអគ្គនាយក ០១រូប ដែលតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល លើកលែងតែតំណាងបុគ្គលិករបស់ **ធ.អ.ជ.ក.** ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ឆ្នាំ។ អាណត្តិនេះអាចបន្តជាថ្មីទៀតបាន តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយមានការឯកភាពពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៩.-**

**ធ.អ.ជ.ក.** ត្រូវបំពេញសកម្មភាព ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា។

**ធ.អ.ជ.ក.** ត្រូវមានក្របខណ្ឌអភិបាលកិច្ចសាជីវកម្មសមស្រប ដើម្បីធានាប្រសិទ្ធភាព សុខភាពហិរញ្ញវត្ថុ និងការរីកចម្រើនប្រកបដោយចីរភាព ដែលត្រូវចែងលម្អិតនៅក្នុងលក្ខន្តិកៈរបស់ **ធ.អ.ជ.ក.**។

**មាត្រា១០.-**

**ធ.អ.ជ.ក.** ត្រូវបន្តនិរន្តភាពគតិយុត្ត រួមទាំងទ្រព្យគ្រប់ប្រភេទរបស់ខ្លួន តាមបទប្បញ្ញត្តិជាធរមាន គិតចាប់ពីពេលដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីធនាគារអភិវឌ្ឍន៍ជនបទ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីធនាគារអភិវឌ្ឍន៍ជនបទ។

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៤ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ១២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ